# ការកាត់ទោសពីបទរាយការណ៍អំពីវិវាទដីធ្លី៖ ករណី លោក ប៉ែន នួន




លោក ប៉ែន នួន ជាអ្នកសារព័ត៌មានក្នុងខេត្តឧត្តរមានជ័យ និងជានិពន្ធនាយកនៃគេហទំព័រស្រទាប់យុវវ័យ ដែលជាបណ្ដាញព័ត៌មានយុវវ័យ បានចុះបញ្ជីជាមួយក្រសួងព័ត៌មានតាំងពី ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥។

## កាលប្បវត្តិចំពោះករណី លោក ប៉ែន នួន

| | |
|---|---|
| **ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩** | បានចុះផ្សាយនូវអត្ថបទរបស់ខ្លួនពីបញ្ហាជម្លោះដីធ្លីរវាងមន្ត្រីឃោជាព្រំដែន និងប្រជាពលរដ្ឋចំនួន៤គ្រួសារ។ |
| **ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០** | លោក ប៉ែន នួន ត្រូវបានសាលាដំបូងខេត្តឧត្តរមានជ័យ សម្រេចផ្ដន្ទាទោសពីបទបរិហាកេរ្តិ៍ជាសាធារណៈតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងផ្ដន្ទាទោសពិន័យជាប្រាក់ចំនួន៤លានរៀល (ប្រហែល១០០០ ដុល្លារ) និងសំណងចំនួន៨០លានរៀល (ប្រហែល២០,០០០ ដុល្លារ) ដល់ដើមបណ្ដឹង។ ក្រោយពីការប្រកាសសាលក្រម លោក ប៉ែន នួន បានប្ដឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ខេត្តបាត់ដំបង។ |
| **ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០** | លោក ប៉ែន នួន បានចេញផ្សាយនូវអត្ថបទថ្មី ទាក់ទងនឹងជម្លោះដីធ្លីនោះដដែល។ ជាលទ្ធផលសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់លោកពីបទបរិហារកេរ្តិ៍តាមសារព័ត៌មាន តាមមាត្រា ៣០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងមាត្រា១០ នៃច្បាប់ស្ដីពីរបបសារព័ត៌មាន ដែលជាបណ្ដឹងបរិហារកេរ្តិ៍មួយទៀតទៅលើលោក ប៉ែន នួន។ |
| **ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១** | សវនាការរបស់លោក ប៉ែន នួន ធ្វើឡើងនៅសាលាដំបូងរាជធានីភ្នំពេញ។ ទោះជាយ៉ាងណា លោក ប៉ែន នួន បានអវត្តមាន ដោយសារទាំងរូបលោក និងមេធាវីរបស់លោក មិនត្រូវបានជូនដំណឹងអំពីថ្ងៃជំនុំជម្រះរបស់តុលាការឡើយ។ សាលាដំបូងរាជធានីភ្នំពេញបានធ្វើការជំនុំជម្រះក្ដីកំបាំងមុខលើករណីបរិហារកេរ្តិ៍តាមសារព័ត៌មាន ចំពោះលោក និងផ្ដន្ទាទោសឱ្យបង់ប្រាក់ពិន័យ ៣ លានរៀល (ប្រហែល ៧០០ ដុល្លារ) និងសំណង៦ លានរៀល (ប្រហែល ១.៥០០ ដុល្លារ) ដល់ដើមបណ្ដឹង។ |
| **ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២** | បន្ទាប់ពីលោក ប៉ែន នួន ប្ដឹងបណ្ដឹងទាស់ទៅលើការកាត់ក្ដីរបស់ខ្លួន សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការសាថ្មីដោយមានវត្តមានលោក ប៉ែន នួន ចូលរួម។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ សាលាដំបូងបានចេញសាលក្រមដូចគ្នាទៅនឹងសាលក្រមកំបាំងមុខ ដែលចេញកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ដែរ។ |
| **ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២** | សាលាឧទ្ធរណ៍ខេត្តបាត់ដំបង តម្កល់សាលក្រមរបស់សាលាដំបូងខេត្តឧត្តរមានជ័យ។ |

ករណីអ្នកសារព័ត៌មាន លោក ប៉ែន នួន គឺជាឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍ជាច្រើននៃការយាយីតាមប្រព័ន្ធតុលាការ ដែលអ្នកសារព័ត៌មានប្រឈមដោយសារតែការអនុវត្តការរាយការណ៍ព័ត៌មានរបស់ខ្លួន និងការបង្ក្រាបជាបន្តបន្ទាប់លើសេរីភាពសារព័ត៌មាននៅកម្ពុជា។ សារព័ត៌មាន សេរី និងគ្មានការត្រួតពិនិត្យ គឺជាកត្តាចាំបាច់ដើម្បីធានាថាសេរីភាពខាងការបញ្ចេញមតិអាចសម្រេចទៅបាន និងភាពរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យ។ សេរីភាពសារព័ត៌មានដើរតួយ៉ាងសំខាន់ក្នុងការជូនដំណឹងដល់សាធារណជន និងឃ្លាំមើលរដ្ឋាភិបាល ធានានូវតម្លាភាព និងគណនេយ្យភាព។ ដូច្នេះសេរីភាពសារព័ត៌មានគួរតែត្រូវបានលើកទឹកចិត្ត និងការពារ ជាជាងការគំរាមកំហែង៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែមេសា ឆ្នាំ២០២២

CC BY NC SA